**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៥០) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:32
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អ.ប.ជ:**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:** **សាធារណៈ/Public**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីសំណុំការអង្គបុរេជំនុំជម្រះទាក់ទងនឹង បណ្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សម្ងាត់ហេតុ)**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោក Nicholas KOUMJIAN

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម BAIK Kang Jin
ចៅក្រម ហួត វុទ្ធី

**សហមេធាវី អ៊ឹម ចែម**
ប៊ិត ស៊ាងលឹម
Wayne JORDASH

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**
**នៃសំណុំរឿង០០៤/១**

# សេចក្តីសន្និដ្ឋាន

1. អនុលោមតាមសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះទៅកាន់ភាគីនានា នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧[1] សហព្រះរាជអាជ្ញាអន្តរជាតិធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម អំពីសវនាការផ្ទាល់មាត់ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សម្អាងហេតុ)[2]។

2. ទីមួយ សហព្រះរាជអាជ្ញាបញ្ជាក់អំពីវត្តមានរបស់ខ្លួននៅថ្ងៃទី១១ និងទី១២ ខែធ្នូ ឆ្នាំ២០១៧។

3. ទីពីរ សហព្រះរាជអាជ្ញាស្នើសុំថា ពេលវេលាដែលបែងចែក ១ ម៉ោង គួរបន្ថែម ១ ម៉ោងទៀត (សរុប ២ ម៉ោង) ដើម្បីធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។ ការបន្ថែមពេលវេលាបែបនេះ គឺមានហេតុផលដោយសារតែមានបញ្ហាជាច្រើនដែលត្រូវលើកឡើង និងសារៈសំខាន់ចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក នេះ[3]។

4. ទីបី សហព្រះរាជអាជ្ញាស្នើសុំថា សវនាការត្រូវធ្វើជាសាធារណៈ ដោយអនុលោមតាមវិធាន ៧៧(៦)[4] នៃវិធានផ្ទៃក្នុង ដោយសារដីកាដំណោះស្រាយ ដែលជាប្រធានបទនៃរឿងក្តីនេះបានរកឃើញថា អ៊ឹម ចែម មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក - មានអានុភាពនាំឲ្យសំណុំរឿងនេះទៅដល់ទីបញ្ចប់។ វិធាន៧៧(៦) នៃវិធានផ្ទៃក្នុង ចែងពីការធ្វើសវនាការជាសាធារណៈ "នៅពេលដែលសំណុំរឿងនោះអាចត្រូវបានបញ្ចប់ ដោយសេចក្តីសម្រេចរបស់ [អង្គបុរេជំនុំជម្រះ] ដូចជាពាក្យបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំពាក់ព័ន្ធទៅនឹងយុត្តាធិការ ឬមូលហេតុដែលនាំឲ្យរលត់បណ្តឹងអាជ្ញា"។ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សវនាការសាធារណៈនៅក្នុងសំណុំ

---

[1] សេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះទៅកាន់ភាគីតាមរយៈសារអេឡិចត្រូនិក, ២៧ តុលា ២០១៧។

[2] **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ៩ សីហា ២០១៧ ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា")។

[3] **D308/3/1/1** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា។ **D308/3/1/9** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីគោលជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា, ៨ កញ្ញា ២០១៧។ **D308/3/1/11** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ២២ កញ្ញា ២០១៧។ **D308/3/1/13** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សម្អាងហេតុ), ១៦ តុលា ២០១៧។

[4] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិ.លើកទី៩), ដោយបានពិនិត្យឡើងវិញ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

រឿង០០៤/១ គឺជា "ប្រយោជន៍យុត្តិធម៌ និងមិនធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ វិធានការការពាររបស់តុលាការឡើយ"[5]។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

5 វិធាន៧៧(៦) នៃវិធានផ្ទៃក្នុង។